# ភាជន៍ដីដុតផលិតនៅភូមិដំណាក់ចំបក់

ចាប សោភារ៉ា និងចាយ វិសុទ្ធ
សារមន្ទីរជាតិភ្នំពេញ

ជាធម្មតា កាលណាពោលពីការផលិតក្អមថ្នាំងប្រើប្រាស់ធ្វើពីដីដុត គេច្រើនគិតទៅខេត្តកំពង់ឆ្នាំងតែប៉ុណ្ណោះ។ តាមពិត បច្ចុប្បន្ននេះមានកន្លែងផលិតច្រើនទៀតនៅប្រទេសកម្ពុជាទាំងមូល ជាពិសេសនៅខេត្តកំពង់ស្ពឺ, តាកែវ, កំពត, កណ្ដាល, បាត់ដំបង។ បើផ្អែកទៅលើការសិក្សារបស់លោក Roland Mourer[១] នៅទសវត្ស ១៩៦០_៧០ ដែលផ្សព្វផ្សាយជាង ២០ឆ្នាំមុននេះ ឃើញថាប្រហែលជាមានការបាត់បង់ខ្លះ តែទោះជាយ៉ាងណាក៏ពុំធ្ងន់ធ្ងរប៉ុន្មានឡើយ។ សូមបញ្ជាក់ថា ខ្ញុំពុំរាប់បញ្ចូលទីដែលផលិតភាជន៍ប្រភេទរឹង មានស្រទាប់រលោងចេញជាសាច់ចានឡើយ ហើយនិយាយតែពីភាជន៍ជាដីដុតធម្មតាដែលត្រូវការកំដៅដែរ តែពុំចាំបាច់ប្រើឡ។ នៅទីនេះ ខ្ញុំសូមបង្ហាញភាជន៍ធ្វើពីដីដុតផលិតនៅភូមិដំណាក់ចំបក់ដែលតាមមើលទៅមានប្រពៃណីជាយូររៀងមកហើយ តែដែលហាក់ដូចជាពុំទាន់មានការសិក្សាស្រាវជ្រាវនៅឡើយ។

ភូមិដំណាក់ចំបក់ស្ថិតនៅក្នុងឃុំសំរោងលើ ស្រុកទូកមាស ខេត្តកំពត ចម្ងាយប្រមាណ១០០គ.ម.ខាងត្បូងភ្នំពេញ។ បរិដ្ឋានជុំវិញភូមិជាស្រែចម្ការ ហើយផុតពីនោះទៅគឺជួរភ្នំ។ ភ្នំមួយដែលជិតជាងគេគឺភ្នំប្រកសៀមជា ទីដែលអ្នកភូមិយកដីមកផលិតភាជន៍ផ្សេងៗ។ ភូមិនេះស្ថិតនៅតាមបណ្ដោយផ្លូវជាតិលេខ៣១ (សូមមើលផែនទី) ហើយសព្វថ្ងៃមានប្រជាជន ៣៦៩ គ្រួសារ។ ជីវភាពអ្នកស្រុកគឺពឹងផ្អែកទាំងស្រុងទៅលើស្រែចម្ការ និងការផលិតភាជន៍។ បច្ចុប្បន្ននេះ ការផលិតភាជន៍ជាពិសេសផលិតជើងក្រាន ក្លាយជារបរមួយដែលអ្នកស្រុកខ្លះធ្វើស្ទើរពេញមួយឆ្នាំ[២]។ ដូច្នេះ របរធ្វើក្អមថ្នាំងជាប្រភពចំណូល

---

[១] Mourer 1986.

[២] ពីមុនមកគេផលិតតែនៅក្នុងរដូវប្រាំងប៉ុណ្ណោះ ពោលគឺចាប់ពីពេលច្រូតកាត់រួចរាល់ហើយទៅទល់ពេលចាប់ផ្ដើមមានភ្លៀងធ្លាក់។ ម្យ៉ាងទៀតធ្វើក្នុងរដូវប្រាំងដូច្នេះស្រួល ដោយសារពុំមានភ្លៀង ហើយមានថ្ងៃស្រួលហាល ព្រមទាំងចង់ដុតពេលណាក៏បានផង។




ទិដ្ឋភាពទូទៅនៃភូមិដំណាក់ចំបក់

សំខាន់សម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ បន្ទាប់ពីស្រែចម្ការ។ បើពោលពីប្រជាជនដែលគ្មានដីធ្វើស្រែចម្ការផង គឺអ្នកនោះពឹងផ្អែកទាំងស្រុងទៅលើរបរនេះ។ បើសួរអ្នកស្រុកថា របរនេះមានពីពេលណាមក គឺគ្មាននរណាដឹងឡើយ ហើយតែងតែឆ្លើយថា ឃើញដូនតាធ្វើមកដូច្នោះឯង។

ប្រការសំខាន់ដែលនាំឲ្យអ្នកភូមិចាប់យកអាជីពនេះ មកពីវត្ថុធាតុសម្រាប់ផលិត មានដីនិងឧសជាដើម ស្ថិតនៅមិនឆ្ងាយពីភូមិ ពោលគឺយកពីភ្នំប្រកសៀមដែលមានចម្ងាយមិនដល់២គ.ម.ផង។ ស្ទួនដែលយកការធ្វើក្អមធ្នាំងនេះជាអាជីព សព្វថ្ងៃមាន៦៥គ្រួសារ។ តែវត្ថុដែលផលិតនោះពុំដូចគ្នាទាំងស្រុងទេ គ្រួសារខ្លះផលិតតែជើងក្រាន ខ្លះផលិតតែអំបែងនំគ្រក់ ឯខ្លះទៀតផលិតរបស់ចម្រុះគ្នា។

### ១–វត្ថុផលិត

ស្ទួននៅភូមិដំណាក់ចំបក់ ផលិតរបស់ប្រើប្រាស់ដែលចាស់ៗធ្លាប់ធ្វើពីមុនមក ពោលគឺផលិតរបស់ប្រើប្រាស់សម្រាប់ដាំស្ល និងភាជន៍សម្រាប់ទុកវត្ថុផ្សេងៗ។ របស់ទាំងនោះគឺ ៖

១.១. “ពឹង” ៖ ភាជន៍ដាក់ទឹករាងស្រដៀងផ្លែឃ្លោក, មានក្អែងធំ, អាចដាក់ទឹកបានប្រមាណ២លីត្រ (អ្នកស្រុកនិយាយថា “ទឹក១ពឹង”)។

១.២. "ក្អម" ៖ ភាជន៍ដាក់ទឹករាងប៉ោង, ករាងស្តួច, ក្អេងដូចផ្លែឃ្លោកសាយជៀវ។

១.៣. "ថ្នាំង" ៖ នៅភូមិនេះថ្នាំងមាន៥ប្រភេទ ៖

- "ថ្នាំងកំប៉េសកាច់ក" ៖ ថ្នាំងដែលមានខ្លួនមូល, កខ្ពស់, ទំហំមាត់តូចងាយស្រួលក្នុងការចាប់កាន់។ ថ្នាំងនេះមាន ក្បាច់ត្រង់ផ្លែបាត, ខ្លួន និងក្អេង។ គេប្រើសម្រាប់ដាំស្ល ម្ហូបអាហារ, ដាំទឹក ឬដាំថ្នាំ (រូបលេខ១) ។
- "ថ្នាំងកំប៉េសមិនកាច់ក" ៖ ដូចថ្នាំងខាងលើនេះ តែមានកខ្លីដូចថ្នាំងដីដែលផលិតនៅខេត្តកំពង់ឆ្នាំងដែរ។ ថ្នាំងនេះមានក្បាច់ត្រង់ក្អេង, បាត និងខ្លួន(រូបលេខ២)។
- "ថ្នាំងអី" ៖ រូបរាងដូចថ្នាំងកំប៉េសមិនកាច់ក តែមានដៃសម្រាប់កាន់ឬញួរ។ ថ្នាំងនេះមានក្បាច់តែនៅត្រង់ក្អេងប៉ុណ្ណោះ។ គេប្រើសម្រាប់ចម្អិនអាហារដែរ(រូបលេខ៣)។
- "ថ្នាំងត្រប៉ែ ឬជើងត្រប៉ែ" ៖ ខ្លួនមូល, មានជើងនិងគម្រប។
- "ថ្នាំងរបួល" ៖ មានរន្ធច្រើននៅបាត ប្រើសម្រាប់ចំហុយនំផ្សេងៗ។(រូបលេខ៤)។

១.៤. "បាត្រ" ៖ ភាជន៍រាងមូលជ្រៅក្រឡួម ប្រើសម្រាប់ដាក់ចង្ហាន់ព្រះសង្ឃ។ ផ្ទៃខាងក្រៅមានពណ៌ខ្មៅរលើប កើតឡើងដោយការលាបកាកល័ក្ត[៣]។ បច្ចុប្បន្ននេះ ស្ទើរលែងបន្តផលិតហើយ ត្បិតគេនិយមប្រើបាត្រធ្វើពីលោហៈ។

១.៥. "ជើង" ៖ រាងរួមក្រោមរីកលើ, មាត់មានគែម, ប្រើសម្រាប់ដាក់ទឹក, លាងចាន, បោកខោអាវ (រូបលេខ៥) ។ល។ ជួនកាលមានចោះបាតសម្រាប់ប្រើជាជើងសម្រាប់ដាំផ្កា ដែលមានលម្អក្បាច់នៅគែមមាត់រាងអង្កាញ់ៗលំនាំទឹករលក។

១.៦. "ឃ្លុះ" ៖ ភាជន៍មានរាងដូចថ្នាំងកំប៉េសកាច់ក តែធំជាងជើង។ ឃ្លុះមាន២យ៉ាង គឺឃ្លុះតូចនិងឃ្លុះធំ។ ការប្រើប្រាស់មានច្រើនបែបយ៉ាង ដូចជាស្ងោរនំ, ដំឡូង, ស្ងោរថ្នាំ, ស្ងោកូនទាង, លីងអំបុក, ដាក់ទឹក, បិតស្រា, បោកខោអាវ, ជ្រលក់សូត្រ ជាដើម (រូបលេខ៦) ។

១.៧. "ថ្លាង" ៖ ភាជន៍នេះទំហំធំ, ពុំមានលម្អក្បាច់នៅលើខ្លួនទេ មានតែនៅចន្លោះ, កនិងក្អេង។ ថ្លាងតែងមានគម្របការពារមិនឱ្យសត្វចូលទៅស៊ីរបស់ដែលគេរក្សាទុក ហើយជួយទប់កម្តៅមិនឱ្យចេញក្រៅនៅពេលស្ងោរនំឬដាំស្ល។ ភាជន៍នេះអាចប្រើស្ងោរនំបានរហូតដល់ទៅ២ដួន (រូបលេខ៧)។

១.៨. "ខ្វាង" ៖ រាងដូចថ្លាងតែទំហំតូចជាង, កខ្លី, មាត់តូច, លម្អដោយល្បាក់មាត់បីគន្លាក់។ ភាជន៍នេះគ្មានក្បាច់នៅលើខ្លួនទេ មានតែនៅចន្លោះ, កនិងក្អេង។ គេអាចដាក់ទឹករហូតដល់ទៅជិត៦០លីត្រ។ បើស្ងោរនំវិញបានរហូតទៅដល់ ៨ដប។

១.៩. "អំបែងនំគ្រក់" ៖ រាងមូលសំប៉ែត, កម្ពស់ប្រមាណ១៥ស.ម., មានរន្ធ៨សម្រាប់ចាក់ម្សៅ។ រន្ធនីមួយៗមាន

[៣] ល័ក្តជាជ័រកើតអំពីសត្វល្អិតមួយពួកនៅដើមឈើ។ កាកល័ក្តគឺល័ក្តដែលគេស្ងោររំងាស់ហើយសម្រាប់បិតវត្ថុផ្សេងៗ ឧទាហរណ៍ យកទៅបិតនង្គ័ល។

គម្របដែលមាន ក្បាច់ផ្សេងៗជាលម្អ។ ផ្នែកខាងលើ មានដៃសម្រាប់ចាប់កាន់ ឬញ្ជឹង *(រូបលេខ៨)*។

១.១០. *"ជើងក្រាន"* ៖ មានប្រភេទច្រើនយ៉ាង គឺ *"ជើងក្រានកាត់មុខ"*, *"ជើងក្រានអង្កាម"*, *"ជើងក្រានផ្សូង"*, និង *"ជើងក្រានយួន"*។

១.១១. *"ស្គរ"* ៖ រាងធំម្ខាងហើយជាសដោយស្បែកពស់។ ស្គរប្រភេទនេះស្ទើរលែងផលិតទៀតហើយ ដោយសារពុំសូវមានការបញ្ជាទិញ។

## ២–ឧបករណ៍ផលិត

ដើម្បីផលិតឲ្យបានជារបស់ប្រើប្រាស់ពីដីដុត ស្មូនប្រើឧបករណ៍សាមញ្ញមួយចំនួនធ្វើដោយវត្ថុធាតុដែលអាចរកបានយ៉ាងងាយពីជុំវិញភូមិដ្ឋាន។ ឧបករណ៍ទាំងនោះមាន ៖

២.១. *"ទ្រនះ"* ៖ បន្ទះឈើ, ឫស្សី ឬត្នោត ប្រវែងប្រមាណ៣០_៤០ស.ម., ជាទូទៅមានរាងស្រួចមកក្រោមសម្រាប់កាន់។ ទ្រនះមានឈ្មោះផ្សេងៗទៅតាមដំណាក់កាលនៃការផលិត *(រូបលេខ ៩)*។ ឧទាហរណ៍ទ្រនះរះ, ទ្រនះបំប៉ោងឬទ្រនះជ្រះ, ទ្រនះបើក និងទ្រនះបិត។ ជួនកាលឈ្មោះផ្សេងពីនេះទៀត ដូចជា ទ្រនះលាត និងទ្រនះគ្រៀតឬទ្រនះក្បាច់។ ទ្រនះក្បាច់ច្រើនធ្វើពីដើមញ្ញ ត្បិតសាច់វាផុយងាយស្រួលចាក់ក្បាច់ ហើយទុកចោលយូរមេមិនស៊ី។ ខ្លះ ហៅឧបករណ៍នេះថា ល្អរ ឬទ្រនេល។

២.២. *"ជ្រនះក"* ៖ ឧបករណ៍រាងទ្រវែងវៀវចុង ធ្វើពីឫស្សី ប្រវែងប្រមាណ២០ស.ម., ទទឹងផ្នែកធំប្រមាណ៣ស.ម., ប្រើសម្រាប់លើកកធ្នាំងឲ្យខ្ពស់ *(រូបលេខ១០)* ។

២.៣. *"គិល"* ៖ ធ្វើពីដីដុត, រាងដូចចុងអង្រែ ពោលគឺមានរាងធំក្រោមវៀវលើ។ ផ្នែកខាងក្រោមប្រើសម្រាប់ទប់ទ្រនះមានលាបកាកល័ក្តដើម្បីកុំឲ្យជាប់សាច់ដីនៅពេលវាយក្រឡឹងពីក្រៅ។ អ្នកភូមិផលិតក្អមឆ្នាំងផ្សេងទៀតហៅឧបករណ៍ប្រភេទនេះថា *"ក្ដឹង" (រូបលេខ១១)*។

២.៤. *"បន្ទះក្ដារ"* ៖ រាងបួនជ្រុងទ្រវែង ទទឹងប្រមាណ៤០ស.ម., ប្រើសម្រាប់សូនដីធ្វើគម្រប ឬប៉ែនឲ្យទៅជាបន្ទះសម្រាប់ធ្វើជាខ្លួនភាជន៍។

២.៥. *"ត្បាល់"* ៖ កំណាត់ដុំឈើ (ដូង ឬត្នោត) កម្ពស់ប្រមាណ៧០ស.ម. ដែលគេកាត់តម្រឹមចុងទាំងសងខាងឲ្យរាបស្មើបញ្ឈរឡើង ដើម្បីដាក់ដីភាជន៍ដែលកំពុងសូន ហើយដើម្បីស្មូនដើរជុំវិញបាន ។ គេហៅថា ត្បាល់ដូច្នេះឯង ទោះបីមិនមានរាងវៀវនៅកណ្ដាល ហើយមិនមែនប្រើសម្រាប់បុកក៏ដោយ។ ទំនងជាពីមុនមកគេយកត្បាល់បុកស្រូវមកប្រើប្រាស់ ទើបបានជាហៅដូច្នេះ។

២.៦. *"ស្លឹកស្រស់"* ៖ ស្លឹកត្របែក ឬស្លឹកជ្រោយ ប្រើសម្រាប់ចាប់ឲ្យចេញជាគែមមាត់ភាជន៍។ មុននឹងប្រើគេយកស្លឹកនេះ ទៅរោលភ្លើងសិនដើម្បីឲ្យស្វិតល្អ។

២.៧. "ខ្សែកាត់" ៖ ខ្សែនីឡុង ដែលគេភ្ជាប់ចុងទាំងពីរខាងទៅនឹងកំណាត់ឈើឬឫស្សីខ្លីៗដើម្បីងាយស្រួលកាន់នៅពេលកាត់គម្របផ្ដាច់ចេញពីរមូរដី។

## ៣. ការផលិត

បច្ចេកទេសពុំមានប្រែប្រួលខុសពីមុនទេ ឧទាហរណ៍គេដើរក្រឡឹងជុំវិញភាជន៍ដោយកាន់ទ្រនុះនិងគិល ពោលគឺពុំមានប្រើឈ្នាន់បង្វិលឡើយ។ អំបែងទំគ្រក់ (៣.៤.) និងជើងក្រាន (៣.៥.) តម្រូវឱ្យមានរបៀបធ្វើផ្ទាល់របស់ខ្លួន តែដំបូងនេះ (៣.១. - ៣.៣. ) ខ្ញុំសង្ខេបអំពីរបៀបធ្វើក្អមថ្នាំងជាទូទៅដែលតែងឆ្លងដំណាក់កាលដូចគ្នាជាមុនសិន។ ដើម្បីបានជាក្អមថ្នាំង គេត្រូវឆ្លងកាត់៥ដំណាក់កាល ពុំខុសអ្វីពីវិធីផលិតរបស់ស្នូននៅកម្ពុជាក្រោម ឬនៅភាគឦសាននៃប្រទេសថៃឡើយ[៤]។ ដំណាក់កាលទាំង៥នោះមាន ៖

### ៣.១. រៀបចំដី

ជាដំបូង គេទៅជីកដីនៅជើងភ្នំច្រកសៀម ដែលមានចម្ងាយប្រមាណ១,៥គ.ម.ភាគពាយ័ព្យភូមិ ។ គេត្រូវប្រុងប្រយ័ត្ននៅពេលជ្រើសរើសយកដីមកប្រើ ត្បិតដីខ្លះអាចបណ្ដាលឱ្យផ្ទុះសាច់ភាជន៍នៅពេលដុត។ តាមធម្មតាគេជីកយកដីថ្មភ្នំនៅស្រទាប់លើចេញ បន្ទាប់មកទើបជីកលុងដីចុះទៅក្រោម។ ពេលខ្លះគេជីកចុះជម្រៅជិត១ម. ទើបទៅដល់ដីមួយស្រទាប់ពណ៌ក្រហម។ តែដីនៅស្រទាប់នេះមិនអាចប្រើបានទេ ព្រោះមានល្បាយថ្មច្រើន មិនសូវស្អិត។ ទាល់តែរហូតដល់ជម្រៅជិត២ម. ទើបដល់ដីថ្នាំង។ ច្រកចូលសម្រាប់លុងយកដីឥដ្ឋមានរាងមូល ឯអង្កត់ផ្ចិតប្រមាណ១ម.។ កម្ពស់មានពី១.៥០ទៅដល់២ម. ល្មមមនុស្សឈរកាប់បានស្រួល (រូបលេខ១២) ឯចម្ងាយវិញអាចមានរហូតដល់១០ម.។ បើរូងនោះកាន់តែវែងទៀត ពេលលុងគេក្រឡឹងទុកជាសសរនៅកន្លែងខ្លះឱ្យទល់ទ្រ ចៀសវាងការបាក់សង្កត់ដោយប្រការណាមួយ។ រូងដីទាំងនេះនឹងបាក់ស្រុត ឬដីហូរចូលពេញវិញនៅរដូវវស្សា។ លុះដល់រដូវប្រាំងក្រោយ គេស្ដារឡើងវិញ ។

បន្ទាប់ពីជីកដីពីភ្នំហើយ គេយករទេះដឹកជញ្ជូនមកផ្ទះរៀងៗខ្លួន។ ដីមួយរទេះ មាន២០បង្គីដែលអាចផលិតក្អមថ្នាំងពី១៨០-២០០ ឬជើងក្រានប្រមាណ១០០។ គេយកដីទៅរាយហាលក្រោមផ្ទះ ឬក្បែរកន្លែងធ្វើក្អមថ្នាំងទាំងនោះ ហើយចាប់ផ្ដើមវាយបំបែកដីដោយត្បូងចប ឬពូថៅឱ្យទៅជាបំណែកតូចៗ ដើម្បីសម្រួលដល់ការបុកដី (រូបលេខ១៣)។ ពេលនោះហើយដែលគេរើសយកដីពណ៌ក្រហមចេញ ព្រោះវាជាដើមហេតុដែលធ្វើឱ្យសាច់ដីផ្ទុះនៅពេលដុត។ គេយកដីនោះ ទៅហាលចោលប្រមាណ៤ទៅ៥ម៉ោង មុននឹងយកទៅបុកឱ្យម៉ដ្ឋល្អ។ កាលពីសម័យមុន គេច្រើនប្រើត្បាល់បុកស្រូវដោយដៃ ដើម្បីបំបែក

[៤] Cort, L. and Lefferts, L. 2000.

ដុំដីឥដ្ឋ តែបច្ចុប្បន្ននេះស្មូននិយមប្រើត្បាល់កៀ្លងជំនួសវិញ ត្បិតងាយស្រួលបំបែកដី *(រូបលេខ១៤)*។ បន្ទាប់មកទៀត គេយកកញ្រែងមួយដែលមានរន្ធទំហំប្រមាណ១ម.ម. ដើម្បីរែងយកក្បាលដីចេញ។ ស្មូនខ្លះប្រមូលក្បាលដីនេះ ច្រកទុកមួយអន្លើ ដើម្បីប្រើប្រាស់នៅពេលក្រោយ។

៣.២. ចាប់រាង

ស្មូនយកដីដែលរែងរួចមកចាក់ជាពុំនូកតូចល្មម រួចហើយយកម្រាមដៃមកកិត្រង់ចំនុចកណ្ដាលឲ្យមានរាងជាក្រឡុក ទំហំប៉ុនផ្លែដូង បន្ទាប់មកទើបដួសទឹកចាក់ចូលមុននឹង ច្របាច់បោកដីនោះឲ្យក្លាយជាដុំដីឥដ្ឋដែលមានទំហំប្រមាណ៣ទៅ ៥គ.ក្រ. ឬធំជាងនេះ អាស្រ័យទៅតាមកម្លាំងធ្វើបាន *(រូបលេខ១៥)*។ ដីនេះហើយ ដែលគេយកទៅចាប់ឲ្យចេញជារាងភាជន៍។ ដំណាក់កាលមានដូចតទៅ៖

- *ប៉ែន*៖ ដំបូងគេចាប់យកដុំដីឥដ្ឋ ទំហំប៉ុនលលាដ៍ដូងមកដាក់លើបន្ទះក្ដារដែលគេបានរោយម្សៅដីឥដ្ឋជាទ្រនាប់ រួចទើបចាប់ផ្ដើមបោកច្របាច់លុញដីឲ្យចេញជារាងមូលទ្រវែងប្រវែងជិតមួយហត្ថ។ គេយកដៃទះដីនោះឲ្យសំប៉ែត ក្នុងកម្រាស់ប្រមាណជា២ទៅ៣ស.ម. ហើយចាប់ចុងទាំងពីរបញ្ឈរបត់ភ្ជាប់មុខគ្នា បង្កើតជារាងបំពង់ដីមួយ ដែលមានកម្ពស់ជិត៣០ស.ម.។ បន្ទាប់មក គេយកម្រាមដៃអូសបន្សុំមុខតំណដោយថែមដីបំពេញត្រង់មុខនោះ ហើយយកទៅហាលមួយរយៈ។ ហាលនោះពុំឲ្យស្ងួតរឹងទេ គឺគ្រាន់តែឲ្យអន់ទន់ជាងមុន ល្មមសម្រាប់ដំណាក់កាលបន្ទាប់។ ពេលនោះ គេបន្តប៉ែនបំពង់ផ្សេងទៀត រហូតគ្រប់ចំនួនដែលគេចង់បាន។ តាមធម្មតាស្មូនអាចធ្វើបានពី ២០ទៅ៣០ដុំក្នុងមួយថ្ងៃ។ សូមបញ្ជាក់ថា នៅដំណាក់កាលនេះ ស្មូនយកម្សៅដីឥដ្ឋរោយលើបន្ទះក្ដារជារឿយៗ ដើម្បីកុំឲ្យដីស្អិតជាប់ពេលបោកច្របាច់។
- *រះ*៖ នៅដំណាក់កាលនេះ ស្មូនយកបំពង់ដីដែលទើបនឹងហាលមកដាក់លើត្បាល់ ដែលនិយាយនៅខាងលើ។ នៅក្បែរត្បាល់គេមានរៀបចំដាក់ធុងទឹកឬជើងទឹក និងដាក់គ្រាំឧបករណ៍សម្រាប់វាយបំប៉ោងខ្លួនភាជន៍ជាច្រើនប្រភេទដែលគេឲ្យឈ្មោះថាទ្រនះ។ នៅដំណាក់កាលដំបូង គេប្រើតែទ្រនះធ្នោតទះក្រឡឹងពីក្រៅ និងយកបាតដៃម្ខាងទៀតទប់ជញ្ជាំងខាងក្នុង *(រូបលេខ១៦)*។ បន្ទាប់មកត្រឡប់ផ្កាប់បំពង់ដីម្ខាងទៀត ដោយធ្វើចលនាដូចគ្នា តែម្ដងនេះគេវាយបង្រួមផ្នែកខាងលើ។ ការប្រើទ្រនះវាយពីក្រៅ គឺដើម្បីធ្វើឲ្យសាច់ដីហាប់ល្អគ្មានខ្យល់ដក់ជាប់ក្នុងជញ្ជាំងភាជន៍ ព្រោះខ្យល់នេះនឹងធ្វើឲ្យផ្ទុះសាច់ដីនៅពេលដុត។ ពេលបានជញ្ជាំងហើយ គេប្រើម្រាមដៃពីរ(ចង្អុលដៃ និងម្រាមកណ្ដាល)រុញពីក្រៅ ហើយយកមេដៃទប់ពីក្នុង រួចអូសក្រឡឹងមួយជុំកន្លះ ដើម្បីកាច់កក្អមថ្នាំងឲ្យចេញជា ក និងគែមមាត់[៥]។ ពេលចេញជារូបរាងកនិងមាត់ថ្នាំងហើយ គេយកទ្រនះធ្នោតវាយគែមមាត់ខាងលើថ្នមៗដើម្បីឲ្យផ្ទៃខាងលើនោះស្មើគ្នា។ គេបង្កើតជាល្បាក់ថ្នារមួយខ្សែ ដើម្បីស្រួលក្នុងការប្រើស្លឹកជ្រោយ ឬស្លឹកត្របែកចាប់គែមមាត់។ ស្លឹកជ្រោយស្រស់នោះមានពីរសន្លឹកត្រួតគ្នា។ ការធ្វើគែមមាត់នេះ ចប់ដោយការប្រើស្លឹកអូសរំលីងសាជាថ្មី។ ហើយទើបគេយកទៅហាលឲ្យស្រពាប់សាច់ដី មុននឹងយកទៅធ្វើនៅដំណាក់កាលបន្ទាប់។

- បំប៉ោង៖ ពេលសាច់ដីឡើងស្រពាប់បន្តិច គេយកបំពង់ដីដែលមានគែមមាត់នោះមកដាក់លើត្បាល់ បន្ទាប់មកទើបប្រើទ្រនះបំប៉ោង ឬទ្រនះជ្រះ ដែលមានផ្ទៃផត និងគិលទ្រាប់ពីក្នុងដើម្បីវាយបំប៉ោងយករាងរបស់ភាជន៍ ពីបាតក្រឡឹងដេញទៅផ្នែកខាងលើ។ ការវាយក្រឡឹងលើកដំបូងនេះ ធ្វើឱ្យផ្ទៃភាជន៍ចេញជារាងកង់។ (រូបលេខ១៧) បន្ទាប់មក គេត្រឡប់ទ្រនះម្ខាងទៀតដែលមានផ្ទៃរាបស្មើវាយពង្រាបសាច់ដីឱ្យស្មើ។ បន្ទាប់ពីនោះគេប្រើទ្រនះកដើម្បីសង្កត់ច្បូតក្រឡឹង កឱ្យរលីងស្អាត និងបង្កើតជាល្បាក់កមួយខ្សែកម្រាស់ប្រមាណពីរធ្នាប់ដៃ។
- បើក ៖ បន្ទាប់ពីបំប៉ោង គេប្រើទ្រនះគ្រាត[៦]ពីរប្រភេទសម្រាប់ទះក្រឡឹងជុំវិញ ដើម្បី បើកឱ្យចេញជារាងក្អមថ្នាំងកាន់តែច្បាស់។ ទ្រនះទាំងពីរ គឺទ្រនះលើកកនិងទ្រនះបើក។ ទ្រនះលើកកសម្រាប់ ប្រថាប់ក្បាច់នៅត្រង់បរិវេណលើក្អែង រីឯទ្រនះបើកសម្រាប់ប្រថាប់ក្បាច់លើខ្លួន(រូបលេខ១៨)។ ដំបូងគេយកទ្រនះលើក កវាយត្រង់ក ឬលើក្អែង បន្ទាប់មកយកទ្រនះបើកមកវាយរះដេញពីផ្ទៃខាងក្រោមទៅផ្នែកខាងលើ ពោលគឺដេញទៅរកក្បាច់ ត្រង់ក្អែង។ សូមបញ្ជាក់ថា ទ្រនះខ្លួនពុំមានផ្ទៃផតដូចទ្រនះបំប៉ោងឡើយ ប៉ុន្តែនៅពេលវាយ ស្មូនទៅតែប្រើគិលទប់ពីក្នុងដូចគ្នា។ វាយបើកតួខ្លួនរួចរាល់ហើយ គេយកទ្រនះកចូតក្បាច់ពីរខ្សែ ត្រង់ចន្លោះកនិងក្អែង។
- វាយបាត៖ នៅដំណាក់កាលចុងក្រោយនេះ ស្មូនយកក្អមថ្នាំងដែលហាលក្បែរនោះមកដាក់លើភ្លៅ ដោយអង្គុយសណ្តូកជើង និងមានដាក់ជើងទឹកដែលមានត្រាំទ្រនះគ្រប់ប្រភេទនៅក្បែរដៃ។ ក្នុងពេលនេះ គេប្រើទ្រនះពីរ គឺទ្រនះជ្រះ និងទ្រនះគ្រាតសម្រាប់វាយបិតបាត។ ដំបូងប្រើទ្រនះជ្រះ និងគិលដើម្បីវាយភ្ជិតបាត ដោយប្រដេញជុំវិញរហូតផ្ទៃបាតរលាយជាប់គ្នាជាសាច់មួយ។ បន្ទាប់មកទើបយកកំណាត់សំពត់មកជ្រលក់ទឹក ហើយខាត់រលីងផ្ទៃបាត រួចចាប់ផ្តើមវាយក្បាច់ដោយទ្រនះគ្រើម ឬទ្រនះលើកកដើម្បីឱ្យផ្ទៃបាតឡើងគ្រាតដូចតួខ្លួន។ គេយកទ្រនះលើកកមកវាយបន្តពី ត្រឹមផ្ទៃដែលមានក្បាច់នៅសល់ពីការប្រើទ្រនះបើក។ សូមបញ្ជាក់ថានៅពេលប្រើទ្រនះលើកកមកវាយផ្ទៃបាត ស្មូនមិនវាយក្រឡឹងជុំវិញដូចដំណាក់កាលមុនៗទេ តែវាយប្រដេញពីក្រោមទៅលើ ពោលគឺត្រឹមផ្ទៃដែលមានក្បាច់ពីទ្រនះបើកប្រដេញ ទៅរកចំណុចកណ្តាលនៃបាតក្អមថ្នាំង។ លុះប្រដេញចប់សព្វគ្រប់ ស្មូនប្រើទ្រនះដដែលនេះទះក្រឡឹងជុំវិញផ្ទៃបាតខាងក្រោមថ្នមៗជា កិច្ចបង្ហើយ (រូបលេខ១៩)។

តាមការសិក្សាស្រាវជ្រាវរបស់ លោក Leedom Lefferts និងអ្នកស្រី Louise Cort នៅតំបន់ផ្សេងៗទៀតក្នុងដំណាក់កាលខាងលើនេះ បច្ចេកទេសធ្វើមានរហូតដល់ទៅ៦បែបផ្សេងគ្នា[៧]។

[៥] នៅដំណាក់កាលកាច់កនេះ គេឧស្សាហ៍ប្រស់ទឹក ឬជ្រលក់ឧបករណ៍ឱ្យសើម ដើម្បីសម្រួលដល់ការអូសគែមមាត់និងការរលីង។

[៦] កាលពីមុន ទ្រនះប្រភេទនេះមានក្បាច់លម្អផ្សេងៗដែលពុំអាចប្រើប្រាស់ឡូកឡំគ្នាឡើយ។ ឧទាហរណ៍ ក្បាច់ផាងដូង គេប្រើសម្រាប់តែលើកក ឯក្បាច់ក្រឡាហូលគេប្រើសម្រាប់តែវាយបើកខ្លួន។ បច្ចុប្បន្ននេះ គេលែងប្រើទ្រនះក្បាច់ទៀតហើយ គឺស្មូនគ្រាន់តែយកឈើមួយបន្ទះមកចូតឱ្យមានស្នាមខ្វង់ជាខ្សែៗស្របគ្នា និងអូសចង្អូរតូចមួយចំផ្នែកកណ្តាលប៉ុណ្ណោះ។

[៧] Lefferts, L. and Cort, L.A. 2003.

៣.៣. ធ្វើគម្រប

គម្របជាដំណាក់កាលចុងក្រោយនិងងាយស្រួលជាងគេ។ ដំបូងគេយកដីមកលុញជារមូរដែលមានទំហំប៉ុនកដើងនិងមានប្រវែង៤០_៥០ស.ម.។ គេយករមូរដីនេះទៅបញ្ឈរលើត្បាល់ បន្ទាប់មកទើបចាប់ផ្តើមដើរក្រឡឹងជុំវិញដោយប្រើមេដៃសង្កត់ចូល បង្កើតជាផ្ទៃក្នុងនិងផ្ទៃក្រៅរបស់គម្រប។ គេយកខ្សែនីឡុងមកកាត់ផ្តាច់យកតួគម្របចេញពីរមូរដីឥដ្ឋ ហើយធ្វើចលនាដដែលៗនេះ រហូតទាល់តែអស់រមូរដុំដីឥដ្ឋ។ សូមបញ្ជាក់ថាស្នូនខ្លះពុំចាំបាច់ប្រើខ្នាតដើម្បីវាស់ផៀបនឹងមាត់ឆ្នាំងឡើយ ត្បិតគេស្ទាត់ដៃត្រូវ។ គម្របដែលចាប់រាងរួចហើយ គេដាក់ហាលចោល ហើយទើបសូនបន្ថែមឲ្យចេញជាក្បាលដោះសម្រាប់ចាប់កាន់មានរាងដូចក្រពុំឈូក។

៣.៤. ការធ្វើអំបែងនំគ្រក់

គេត្រូវមានឧបករណ៍មួយចំនួនដូចតទៅ ៖ ពុម្ពអំបែងនំគ្រក់, ក្តារឈើមួយបន្ទះ, កំណាត់សំពត់មួយបន្ទះ, កងធ្វើពីឫស្សី, ឧបករណ៍មួយទៀតជាបន្ទះឫស្សីស្តើងដែលគេពត់កោងពាក់កណ្តាល រង្វង់ភ្ជាប់ចុងពីម្ខាងទៅម្ខាងដោយខ្សែនីឡុង, កូនកាំបិត ឬឫស្សីស្តើង, អង្រែខ្វង, អង្រែតប់, ដុំឥដ្ឋនិងឫស្សីមូលទំហំប៉ុនម្រាមដៃ (នៅរូបលេខ៩ពុំមានវត្ថុខាងក្រោយនេះ ទេ)។

- អង្រែខ្វង ៖ ធ្វើអំពីដីដុត, ផ្ទៃខាងលើរីកឡើងចេញរាងក្រឡូមដូចផ្សិត, ចុងដងដែលភ្ជាប់ទៅនឹងគន្លាក់រីកធំនោះមានដុំដីឥដ្ឋបិតភ្ជាប់ ដើម្បីស្រួលកាន់។
- អង្រែតប់ ៖ មានរាងស្រដៀងនឹងអង្រែខាងលើដែរ តែផ្នែកខាងលើរាបស្មើ។

មុនដំបូងស្នូនរៀបចំចម្លងពុម្ពប្រមាណ១០ចេញពីពុម្ពមេ។ ពុម្ពចម្លងនេះមានកម្រាស់ស្តើងជាងពុម្ពមេ ហើយគេយកដីឥដ្ឋសើមមកមកច្របាច់ឲ្យរាបស្មើនៅក្នុងកងឫស្សីដែលដាក់ពីលើកំណាត់សំពត់។ ពេលផ្ទៃដីឥដ្ឋរាបស្មើហើយ គេយកធ្នូឫស្សីមកកាត់ផ្ទៃ ខាងលើដែលហៀរលើសកម្រាស់កងចេញ បន្ទាប់មកយកបន្ទះដីទៅផ្កាប់នៅលើពុម្ព រួចទើបដកកំណាត់សំពត់ចេញ។ គេយកដីទៅបិតភ្ជាប់នឹងបន្ទះដីនេះដើម្បីធ្វើជាជញ្ជាំង។ លុះចេញជាជញ្ជាំងហើយ គេខ្វងរន្ធទាំង៨របស់ពុម្ពដោយប្រើអង្រែខ្វង។ បើខ្វងទៅមានស្នាមប្រេះ គេយកដីទៅបិតស្នាមទាំងនោះ។ បន្ទាប់មកទើបប្រើអង្រែតប់មកបង្ហាប់ដីត្រង់កន្លែងដែលបិតបន្ថែម។ ពេលតប់រួចរាល់ គេខ្វងម្តងទៀត មុននឹងដាក់ហាលឲ្យសាច់ដីស្រពាប់ល្អ។ ពេលដីស្រពាប់ល្អហើយស្នូនយកសម្បកគ្រុំរំលីងឲ្យផ្ទៃស្មើល្អ រួចហើយទើបខ្វងមួយលើកទៀត។ ប្រសិនបើមានសាច់ដីផុសឡើង គេយកសម្បកខ្យងរំលីងម្តងទៀត មុននឹងយកម្រាមដៃជ្រលក់ទឹករំលីងជាលើកចុងក្រោយ។ នៅដំណាក់កាលបន្ទាប់ គេដកអំបែងចេញពីពុម្ពយកទៅហាលឲ្យស្រពាប់ ទើបសំអាតបាត ដោយប្រើឫស្សី និងកំណាត់ជូតរំលីងជាបញ្ចប់។

សូមសង្កេតថា អំបែងនំគ្រក់នៅភូមិដំណាក់ចំបក់ មានគម្របធ្វើពីពុម្ពដីឥដ្ឋចៅសម្រាប់បិតរន្ធនីមួយៗ។ គម្របនោះមានដោះសម្រាប់កាន់និងក្បាច់លម្អ។ ដំបូងគេយកដីមកលុញឲ្យបានរាងទ្រវែង កម្រាស់ប្រមាណ១០ស.ម. តែរួមតូចផ្នែកម្ខាង។ គេយកផ្នែករួមតូចនោះដាក់ចូលក្នុងពុម្ព រួចទើបច្របាច់ឲ្យហាប់រាបស្មើទៅនឹងគែមពុម្ព មុននឹងយកមេដៃរុញទ្បៀល

ឲ្យចេញជាផ្ទៃផត។ គេយកកូនកាំបិតចៀរសាច់ដីដែលផុសចេញមកផុតគែមពុម្ព បន្ទាប់មកទើបយកដៃជ្រលក់ទឹករំលីងគែមមាត់នឹងផ្ទៃខាងក្នុងគម្រប។ រួចហើយ គេដាក់ហាលចោលមួយស្របក់ ទើបចាក់ចេញពីពុម្ព រួចដាក់ហាលចោលឲ្យស្ងួត ទើបយកមកតម្រឹមដាយគែមជាមួយនឹងដុំឥដ្ឋ មុននឹងយកទៅដុត។

៣.៥. ការធ្វើជើងក្រាន

សព្វថ្ងៃនេះ ជើងក្រានដែលផលិតនៅភូមិដំណាក់ចំបក់មាន៤ប្រភេទ ហៅថាជើងក្រានឱស, ជើងក្រានធ្យូង[៨], ជើងក្រានអង្កាមនិងជើងក្រានយួន។ រីឯបច្ចេកទេសធ្វើ គឺប្រហាក់ប្រហែលគ្នា លើកលែងតែជើងក្រានយួន *(រូបលេខ២០)* ដែលប្រើពុម្ពសង្កត់[៩]។

ដំណាក់កាលដំបូងនៃការធ្វើជើងក្រានដូចគ្នាទៅនឹងការធ្វើក្អមថ្នាំងដែរ ពោលគឺចាប់ផ្ដើមពីការប៉ែននិងភ្ជាប់មុខតំណបង្កើតជាបំពង់រាងមូល និងប្រើទ្រនះត្នោតរះឲ្យផ្ទៃជញ្ជាំងរាបស្មើ។ ពេលរះ គេប្ដូររូបរាងបំពង់នេះទៅជាខ្លួនជើងក្រាន ពោលគឺឲ្យចេញរាងរួមក្រោមរីកលើ ឯត្រង់ផ្នែកខាងក្រោមបត់ចូលបន្តិចសម្រាប់ភ្ជាប់បន្ទះទៅនឹងបន្ទះបាត ដែលមានអង្កត់ផ្ចិតប្រមាណ២០ស.ម.។ គេដាក់បំពង់ដីឥដ្ឋនេះហាលនៅក្នុងម្លប់ បន្ទាប់មកទើបចាប់ផ្ដើមធ្វើបន្ទះបាត។ បន្ទះបាតនេះ មានរាងមូលក្រាស់និងមានអង្កត់ផ្ចិត១០ស.ម. រាងដូចដុំមេដំបែបិតស្រា។ រួចគេយកបន្ទះនោះទៅទះឲ្យស្ដើងសម្រាប់ភ្ជាប់បន្ទះទៅនឹងខ្លួនជើងក្រានដែលដាក់នៅលើត្បាល់។ ក្រោយមក គេយកទ្រនះជ្រះមកវាយរំលីងជញ្ជាំងខាងក្រៅឲ្យរាបស្មើ, ធ្វើគែមមាត់និងភ្ជិតតំណបាតជាមួយខ្លួនជើងក្រាន។ គេយកកាំបិត ឬឫស្សី ចៀរបន្ទះដីដែលធំជាងផ្ទៃបាតចេញ និងយករម្ចូរដីប៉ុនម្រាមដៃទៅបៀកភ្ជិតត្រង់មុខតំណផ្នែកខាងក្នុងវិញ។ រួចរាល់ហើយ គេយកតួជើងក្រាននេះហាល ឲ្យសាច់ដីស្រពាប់ ទើបយកដោះទាំងបី[១០] ទៅភ្ជាប់និងកាត់មុខសម្រាប់ដាក់ឱស។ ជើងក្រានប្រភេទនេះ ហៅថាជើងក្រានកាត់មុខ *(រូបលេខ២១)*។

ឯជើងក្រានធ្យូងនិងជើងក្រានអង្កាមវិញ *(រូបលេខ២២)* បច្ចេកទេសធ្វើខុសពីជើងក្រាន កាត់មុខនៅដំណាក់កាលនេះ។ ជើងក្រានធ្យូងមានកាត់មុខដែរ តែមិនបង្ហួសដល់បាតឡើយ។ គេកាត់ត្រង់ផ្ទៃ១/២នៃជើងក្រាន ឯផ្នែកខាងក្រោមនៃមុខកាត់នេះ គេចោះប្រហោងមួយទៀតសម្រាប់កាយផេះចេញ។ នៅផ្នែកខាងក្នុង គេបន្ថែមដោះតូចមួយនិងគែមទ្រវែងពាសនៅជាប់នឹងគែមខាងលើនៃប្រហោង។ ដោះតូចនិងគែមខាងក្នុងនេះ មានមុខងារទ្របន្ទះមូលដែលមានចោះរន្ធតូចសម្រាប់ឲ្យផេះធ្លាក់មកក្រោម។ ឯជើងក្រានអង្កាមវិញ នៅដំណាក់កាលនេះ គេពុំកាត់មុខឡើយ តែគេចោះប្រហោងកោងធំមួយនៅផ្នែខាងក្រោម។ ប្រហោងនោះ គេយកបន្ទះដីភ្ជាប់បន្តនឹងផ្នែកកោងលយទៅក្នុងប្រមាណ១០ស.ម. ដើម្បីឲ្យមានមុខខ្យល់ចេញចូលពេលដុត។

---

[៨] ជាទូទៅគេចាប់ផ្ដើមផលិតជើងក្រានធ្យូងនៅក្រោយឆ្នាំ១៩៧៩។

[៩] ជើងក្រានយួនទើបតែចាប់មានផលិតប៉ុន្មានឆ្នាំមកនេះប៉ុណ្ណោះ។ ខ្ញុំពុំរៀបរាប់ពិស្ដារអំពីការផលិតជើងក្រានថ្មីនេះទេ។

[១០] តំបន់ខ្លះគេហៅថាម៉ុចង្ក្រាន។

### ៣.៦. ដុត

ស្មូនទៅភូមិដំណាក់ចំបក់ មិនប្រើឡឬគុកសម្រាប់ដុតក្អមថ្នាំង និងជើងក្រានទេ តែនិយម “ដុតលាត” ឬដុតហាលវាល។ ការដុតនេះចែកជាបីដំណាក់កាល ៖ មុនពេលដុត, ពេលដុត និងក្រោយពេលដុត។

- មុនពេលដុត ៖ គេហាល ឬផ្អើរសាច់ដីឲ្យស្ងួតល្អមុននឹងយកទៅដុត។ ការធ្វើឲ្យស្ងួតនេះជួយឲ្យសាច់ដីរឹងល្អ ធន់នឹងកម្ដៅភ្លើង ពោលគឺមិនផ្ទុះ ឬបែកសាច់ដីក្នុងពេលដុតឡើយ។ បើសិនហាលឬផ្អើរទៅមានស្នាមប្រេះ គេយកដីបិតភ្ជិតភ្លាមៗនៅពេលនោះតែម្ដង។ ក្រៅពីការហាលក្អមថ្នាំង គេរៀបចំទីកន្លែងសម្រាប់ដុត ដោយពង្រាបដីឲ្យស្មើល្អ រួចទើបយកឧសទៅតម្រៀបពីលើផ្ទានោះ។ ជួនកាលនៅត្រង់បាតកន្លែងដុតនេះ មានតម្រៀបថ្មធំៗពីក្រោម ដើម្បីការពារសំណើមពីក្នុងដី។ បើដុតនៅរដូវវស្សា ស្មូនខ្លះយកក្បាលដី[១១] ទៅក្រាលថែមពីលើ មុនពេលរៀបឧស ដើម្បីជួយកាត់បន្ថយសំណើម។ ដំណាក់កាលនេះមមាញឹកជាងគេ ហេតុដូច្នោះស្មូនខ្លះត្រូវការជំនួយពីសមាជិកគ្រួសារដើម្បីរៀបចំទីផ្ទាដុតនិងជួយកិច្ចការផ្សេងៗទៀត។ បន្ទាប់មក គេយកឧស[១២] ដែលមានទំហំប៉ុនម្រាមដៃមករាយផ្ដេកលើគ្នាពីរជាន់ ទើបយកភាជន៍ដែលត្រូវដុតមករៀបត្រួតលើគ្នាជាជួរៗ និងបន្ថែមឧសនៅចន្លោះជួរទាំងនោះ ដើម្បីឲ្យភ្លើងឆេះសព្វល្អ។ នៅជុំវិញគំនរឧសនេះ គេយកជើងក្រាន ឬក្អមថ្នាំងដែលបាក់បែកមករាយបន្ថែមទប់ឧសកុំឲ្យធ្លាក់ រួចយកចម្បើងនិងឧសមួយចំនួនមករាយគ្របពីលើគំនរនោះ (រូបលេខ ២៣_២៤)។
- ពេលដុត ៖ គេចាប់ផ្ដើមដុតគំនរភាជន៍នេះ ដោយយកចម្បើងមករាយដុតបណ្ដាក់ជុំវិញនោះ។ ដើម្បីឲ្យសាច់ក្អមថ្នាំងឆេះសុះនិងឆ្អិនល្អ គេត្រូវដើរក្រឡឹងជុំវិញថែមចម្បើងឬឧសជាញឹកញាប់ នៅត្រង់ផ្ទៃដែលភាជន៍លេចនៅកណ្ដាលវាល។
- ក្រោយពេលដុត ៖ គេទុកឲ្យក្អមថ្នាំងទាំងនោះចុះត្រជាក់មួយស្របក់សិន មុននឹងលើកចេញពីគំនរនោះ។ ក្អមថ្នាំងមួយចំនួនខូចរូបរាង ដោយសារសាច់ដីផ្ទុះក្នុងពេលដុត ឬមានស្នាមខ្មៅរោលជាប់នៅលើ ខ្លះទៀតមិនទាន់ឆ្អិនសព្វល្អ។ ភាជន៍ណាដែលមិនទាន់ឆ្អិនល្អ គេប្រមូលយកទៅទុកមួយកន្លែង ដើម្បីដុតនៅពេលក្រោយម្ដងទៀត។ ភាជន៍ដែលឆ្អិនល្អតែងមានពណ៌ក្រហមស្អាត, សាច់ដីរឹងល្អ និងរំលេចដោយកំទេចមាសផ្លេកៗនៅជាប់នោះ[១៣]។

[១១] ជាសំណល់ដីដែលសល់ពីការវែង។

[១២] ឧសដុតមិនចាំបាច់ឈើធំៗឡើយ គឺអាចជាឫស្សីតូចៗ, កូនឈើ, មែកឈើ, ធាងដូង, ធាងត្នោត។ល។ ពោលគឺរបស់ដុតដែលអាចរកបាននៅជុំវិញភូមិ។

[១៣] ស្មូននៅភូមិនេះច្រើនជឿថា មានតែភូមិដំណាក់ចំបក់ទេដែលដីដុតទៅមានកំទេចមាសនៅជាប់សាច់ភាជន៍។ ប៉ុន្តែ យើងធ្លាប់ប្រទះឃើញកំទេចមាសដូចគ្នានេះនៅខេត្តកំពង់ឆ្នាំង ពោលគឺក្អមថ្នាំងដែលយកដីមកពីភ្នំក្រាំងដីមាស។

## ៤. ក្បាច់លម្អ

សព្វថ្ងៃ ភាជន៍ផលិតនៅភូមិនេះ ពុំសូវមានក្បាច់លម្អច្រើនបែបយ៉ាងដូចកាលពីមុនឡើយ។ ជាទូទៅ ក្បាច់លម្អទាំងនេះកើតឡើងពីទ្រនះឈើ ដែលគេយកមកទះដូចមាននិយាយនៅកំណត់យោងលេខ១៦។ បើតាមការស្រាវជ្រាវរបស់លោក R. Mourer នៅភូមិផ្សេងទៀត ក្បាច់លើទ្រនះមានរហូតដល់ ទៅ១០ប្រភេទពោលគឺ ក្បាច់គ្រាតក្រោម, ក្បាច់ឈូក, ក្បាច់ភ្នែកមាន់, ក្បាច់សំណាញ់, ក្បាច់ជើងក្ដាម, ក្បាច់ផ្កាច័ន្ទ, ក្បាច់សីមា, ក្បាច់ធាងដូង, ក្បាច់ក្រឡាកញ្ចក់, និងក្បាច់សណ្ដូក[១៤]។

ក្បាច់លម្អក្អមឆ្នាំងដែលនិយមនៅភូមិដំណាក់ចំបក់ចែកចេញជាបីផ្នែកសំខាន់ៗគឺ ៖

- ក្បាច់លម្អត្រង់កនិងក្អេង ជាក្បាច់ដែលមានលំនាំបញ្ឈរចុះក្រោមកើតពីការទះដោយទ្រនះលើកក។ ពីមុនមក គេមានប្រើក្បាច់ដាច់ដោយឡែកពីគ្នា ឧទាហរណ៍ ក្បាច់ធាងដូងប្រើសម្រាប់តែលម្អនៅត្រង់ក ឯក្បាច់ក្រឡាហូលវិញគេប្រើជាលម្អនៅត្រង់ខ្លួន។ ក្រៅពីក្បាច់សំខាន់នេះ គេយកក្បាច់ចូតពីរខ្សែ អូសកាត់ពីលើក្បាច់ប្រថាប់នៅត្រង់ក្បែរកក្អម ឬឆ្នាំង។
- ក្បាច់លម្អត្រង់ខ្លួន ពោលគឺនៅត្រង់ចន្លោះក្អេងនិងបាត មានលំនាំជាខ្សែផុសកាត់ពីលើក្បាច់បញ្ឈរឬផ្ដេកបញ្ឆិត។ ក្បាច់ទាំងនេះកើតឡើងពីការវាយទ្រនះបើក។ ដើម្បីបានទ្រនះមកវាយចេញជាក្បាច់នេះ គេយកបន្ទះឈើមកចូតជាចង្អូរទទឹង ឲ្យចេញជាស្នាម ធ្នូត និងធ្វើចង្អូរបណ្ដោយមួយនៅចំកណ្ដាល។ កាលណាវាយលើផ្ទៃភាជន៍ក៏ផុសចេញជាខ្សែ។
- ក្បាច់លម្អត្រង់បាត ជាក្បាច់នៅផ្ទៃខាងក្រោមបង្អស់នៃភាជន៍ កាលណាគេបិតក្ឆិតបាតរួចរាល់ហើយ។ ក្បាច់នេះបានពីការប្រើទ្រនះលើកក។

បច្ចុប្បន្ននេះ ក្បាច់លម្អទាំងអម្បាលម៉ានខាងលើ ជាទូទៅក្លាយជាអត្តសញ្ញាណសម្គាល់ផលិតផលនៃភូមិដំណាក់ចំបក់នេះ។

## ៥– ស្ថានភាពបច្ចុប្បន្ននិងការវិវឌ្ឍន៍

មកទល់ពេលនេះ ស្ទូននៅភូមិដំណាក់ចំបក់ព្យាយាមរក្សាបច្ចេកទេសធ្វើក្អមឆ្នាំងតាមបែបប្រពៃណី សម្រាប់ផលិតវត្ថុដូចតទៅ ៖ ក្អម, ឆ្នាំង (ឆ្នាំងរបួល, ឆ្នាំងអី, ឆ្នាំងកំប៉ែសកាច់ក និងមិនកាច់ក) ពីង, ជើង, ថ្លាង, ខ្វាង, ឃ្លុះ, ជើងក្រាន (ជើងក្រានកាត់មុខ, ជើងក្រានអង្កាម, ជើងក្រានយួន), អំបែងទំគ្រក់, បាត្រព្រះសង្ឃ និងស្គរដី។

---

[១៤] Mourer 1986: 272-277.

ទោះបីជាស្នូនប្រឹងប្រែងរក្សាប្រពៃណីចាស់បុរាណនេះយ៉ាងណាក៏ដោយ ក៏ការវិវឌ្ឍន៍នៃសង្គមបច្ចុប្បន្នកំពុងធ្វើឱ្យវិស័យផលិតភាជន៍នេះ ឱនថយបន្តិចម្តងៗ។ កត្តាមានច្រើនយ៉ាង ក្នុងនោះមានទីផ្សារដែលជាកត្តាសំខាន់បំផុត។ វត្ថុប្រើប្រាស់មួយចំនួនធំដែលពីមុនមកគេផលិតជាភាជន៍ដីដុត សព្វថ្ងៃនេះមានវត្ថុពីលោហៈ និងជ័រប្លាស្ទិកនាំចូលពីប្រទេសជិតខាងមកជំនួស ដូច្នោះហើយបានជាគេស្ទើរតែបោះបង់ចោលជាស្ថាពរនូវការផលិតភាជន៍ធំៗ ដូចជាខ្ទះ, ឃ្លុះ និងថ្លាង។ ទាល់តែស្នូនមានវ័យចំណាស់ទើបមានបទពិសោធន៍គ្រប់គ្រាន់នឹងធ្វើវត្ថុទាំងនោះ រីឯស្នូនវ័យកណ្តាលមានតិចណាស់ដែលចេះធ្វើ។ នេះគឺមកអំពីទីផ្សារនោះឯង ត្បិតបើមានការបញ្ជាទិញ បច្ចេកទេសផលិតនោះពុំអាចបាត់បង់ទៅណាឡើយ។ តែទោះជាយ៉ាងណាក៏នៅមានគ្រួសារមួយចំនួនតូចនិយមប្រើភាជន៍ដីដុតនៅឡើយដែរ ថ្វីត្បិតតែជាមនុស្សភាគតិច។ នេះមកអំពីគេយល់ថា អាហារដែលចម្អិនក្នុងឆ្នាំងដីមានរសជាតិឆ្ងាញ់ បើជាថ្នាំរុក្ខជាតិវិញគឺមានប្រសិទ្ធភាព *(រូបលេខ១២៥-២៧)*។ បើពោលពីភាជន៍ធំៗវិញក៏ដូចគ្នា គឺថាការប្រើភាជន៍ដែលមានពីប្រពៃណីមកមានការចុះថយខ្លាំងណាស់។ ឧទាហរណ៍ នៅរដូវភ្ជុំបិណ្ឌកន្លងមកនេះយើងសង្កេតឃើញថាមានតែផ្ទះមួយចំនួនតូចប៉ុណ្ណោះដែលនៅប្រើភាជន៍ដូចជាឃ្លុះនិងថ្លាងដើម្បីស្ងោរអន្សម *(រូបលេខ១២៨-២៩)*។ រីឯភាជន៍ប្រភេទបុរាណខ្លះទៀតក៏ស្ទើរតែបាត់ដូចគ្នា ប្រសិនបើប្រទះឃើញប្រើ ក៏ករណីនោះជាភាគតិចណាស់។ ឃ្លុះដែលដាក់អង្ករ *(រូបលេខ១៣០)* និងថ្លាងដែលដាក់ទឹក *(រូបលេខ១៣១)* នេះ ជាឧទាហរណ៍ដែលមានដោយកម្រ។ បើពោលពីការប្រើឃ្លុះតម្រួតគ្នាដើម្បីបិទស្រា ដែលជាបច្ចេកទេសពិសេសមួយនោះ គឺសព្វថ្ងៃបាត់បង់ទាំងស្រុងទៅហើយ។

រីឯជើងក្រានវិញ គេអាចគិតស្មានថាទៅអនាគតនឹងនៅសល់តែប្រភេទ "ជើងក្រានយួន" ប៉ុណ្ណោះ ដែលមនុស្សនឹងបន្តផលិត រីឯជើងក្រានដទៃទៀតប្រហែលជានឹងបោះបង់ចោល។ នោះក៏ជាតម្រូវការនៃទីផ្សារដែរ។ ក្រៅអំពីនេះ ការវិវឌ្ឍន៍សេដ្ឋកិច្ចជាទូទៅនៅក្នុងប្រទេសក៏ជះឥទ្ធិពលខ្លាំងធ្វើឱ្យវិស័យនេះចុះថយដែរ។ យុវជនប្រុសស្រីមួយចំនួនចាកចេញពីភូមិមកនៅតាមតំបន់ក្រុងនានាដើម្បីប្រកបការងារផ្សេងទៀត ដូចជាធ្វើកម្មករតាមរោងចក្រ, ការដ្ឋានសំណង់ ឬក៏ប្រកបអាជីពផ្សេងពីនោះទៅទៀត។ បើពិនិត្យមែនទែនទៅ អ្នកដែលក្រាញនៅភូមិបន្តធ្វើរបរក្អមឆ្នាំង ពុំគិតគូររករបរថ្មីនោះច្រើនតែជាមនុស្សចាស់ដែលកម្លាំងកាយខ្សត់ខ្សោយផង[១៥]។ ទីផ្សារដែលប្រែប្រួលនេះក៏ធ្វើឱ្យបច្ចេកទេសប្រែប្រួលខ្លះដែរ។ បើយករបៀបដុតមកនិយាយ គឺថានៅមុនឆ្នាំ១៩៧៥ ស្នូននៅភូមិដំណាក់ចំបក់ប្រើគុក (ឡបើកចំហ) សម្រាប់ដុតក្អមឆ្នាំង។ តែសព្វថ្ងៃនេះលែងឃើញប្រើគុកទៀតហើយ គឺគេនិយមដុតហាលវាលតែប៉ុណ្ណោះ។

អនាគតទៅមុខនឹងបង្ហាញយើងថាតើបេតិកភណ្ឌអរូបី ពោលគឺជំនាញផលិតភាជន៍ដីដុតដែលអ្នកស្រុកដំណាក់ចំបក់មានពីដូនតាមកនឹងបាត់បង់ជាស្ថាពរ ឬមួយនឹងបត់បែនប្រែប្រួលទៅតាមទេសកាល ដោយមានវត្ថុអ្វីថ្មីផលិតជាជំនួសវត្ថុដែលបាត់បង់។

---

*[១៥] សូមជ្រាបថាភាជន៍ដែលមានរូបរាងធំ តម្រូវឱ្យប្រើកម្លាំងកាយច្រើន។ ស្នូនដែលមានចំណាស់សព្វថ្ងៃនៅចងចាំបច្ចេកទេសធ្វើ តែទោះជាមានគេបញ្ជាទិញម្តងៗ ក៏ពុំអាចទ្រាំទ្រនឹងការងារនោះបានទេ។ កាលពីជំនាន់ដែលអ្នកទាំងនោះនៅក្មេង អ្នកខ្លះអាចធ្វើរហូតទៅដល់ពាងដាក់ទឹកដែលមានកម្ពស់៧០ស.ម. និងអង្កត់ផ្ចិតផ្នែកធំ៧៣ស.ម។*


កាប់ដី
រៀបចំដី
ច្របាច់ដី
ដុំដីឥដ្ឋ
ប៉ែន
វះ
បំប៉ោង
រៀបចំបាត
តបាត
កាត់មុខ
ជើងក្រាន
បើក
វាយបាត
ផ្ញើគម្រប
ក្អមថ្នាំង
ដុត
ប្រើប្រាស់
លក់


រូបលេខ១


រូបលេខ២


រូបលេខ៣


រូបលេខ៤


រូបលេខ៥


រូបលេខ៦


រូបលេខ៧


រូបលេខ៨


រូបលេខ៩


រូបលេខ១០


រូបលេខ១១


រូបលេខ១២


រូបលេខ១៣


រូបលេខ១៤


រូបលេខ១៥


រូបលេខ១៦



រូបលេខ១៧



រូបលេខ១៨



រូបលេខ១៩



រូបលេខ២០



រូបលេខ២១



រូបលេខ២២



រូបលេខ២៣



រូបលេខ២៤


រូបលេខ២៥


រូបលេខ២៦


រូបលេខ២៧


រូបលេខ២៨


រូបលេខ២៩


រូបលេខ៣០


រូបលេខ៣១

# ឯកសារយោង

Cort, L.A. and Lefferts, L.,2000, " Khmer Earthenware in Mainland Southeast Asia: An Approach Through Production," *UDAYA* I: 55-51.

Lefferts L., and Cort, L., 2003, "A Preliminary Cultural Geography of Contemporary Village-based Earthenware in Mainland Southeast Asia" *in* John N. Miksic, ed., *Earthenware in Southeast Asia,* Southeast Asian Ceramic Society, Singapore: 300-310.

Mourer, R., 1986, *La poterie au Cambodge : histoire et développement. Essai d´ethno-technologie,* Thèse de doctorat, Ecole des Hautes Etudes en Sciences Sociales (EHESS). Paris.

## សង្ខេប

*ភាជន៍ដីដុតផលិតនៅភូមិដំណាក់ចំបក់*

ដោយ ចាប សោភារ៉ា និង ចាយ វិសុទ្ធ

នេះជាលើកទីមួយហើយដែលមានការស្រាវជ្រាវអំពីកុលាលភាជន៍នៅភូមិដំណាក់ចំបក់ក្នុងខេត្តកំពត។ ការប្រៀបធៀបស្ថានភាពបច្ចុប្បន្នទៅនឹងប្រពៃណីដែលមានពីមុនមកមានសារសំខាន់ណាស់ ព្រោះបើពិនិត្យអំពីកត្តាផ្ទៃក្នុង ឃើញថាមិនសមមានអ្វីមកធ្វើឲ្យអាជីពនេះប្រែប្រួលខ្លាំងឡើយ។ ដូច្នេះការវិវឌ្ឍន៍ខ្លាំងសព្វថ្ងៃ គឺមកអំពីការវិវឌ្ឍន៍ទីផ្សារដែលជាមូលហេតុធំ។ តើឧទាហរណ៍នៅទីនេះដូចគ្នានឹងស្ថានភាពទីផ្សេងៗដែលផលិតភាជន៍ដីដុតដែរឬអ្វី? អ្នកសិក្សាស្រាវជ្រាវអាចយកករណីនេះទៅជាជំនួយក្នុងពិចារណា។

**Résumé**

*La production de poterie au village de Damnak Chambâk*

Chap Sopheara and Chay Visoth

Il s'agit ici d'une ébauche d'étude sur la production de poterie au village de Damnak Chambâk, en Kampot. Comparer la situation présente avec celle du passé s'avère d'un grand intérêt, car rien des facteurs internes ne semble justifier les changements observés. Il apparaît dès lors que l'évolution du marché d'aujourd'hui en constitue le facteur essentiel. L'exemple de Damnak Chambâk est-il représentatif des autres centres de production de poterie en terre cuite? C'est indubitablement un élément de réflexion pour les chercheurs dans ce domaine.

**Abstract**

*The Pottery production in the village of Damnak Chambak*

Chap Sopheara and Chay Visoth

This is the first phase of a study of pottery production in the village of Damnak Chambak, in Kampot. A comparison of the present and the past proves of interest as no internal factors would appear to explain changes observed: It seems that the evolution of today's market is instead key. Is Damnak Chambak representative of other centers of pottery production? It undoubtedly provides scholars working in this field material for further thought.